| | |
|---|---|
| សេចក្តីប្រកាសព័ត៌មាន | ហាមចេញផ្សាយមុនម៉ោង 00:01 amថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៨ |

# ក្រុមអ្នកបរិស្ថានក្រើនរំលឹកប្រតិភូដែលមកចូលរួមប្រជុំអំពីតំបន់រ៉ាំសា Ramsar លើតំបន់ដីសើមតាមដងទន្លេមេគង្គដែលកំពុងប្រឈមទៅនឹងគ្រោះថ្នាក់ ដោយសារគម្រោង ហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំៗ

**ភ្នំពេញ ប្រទេសកម្ពុជា** - ក្នុងនាមជាប្រតិភូមកពីរដ្ឋាភិបាលនៃប្រទេសអាស៊ី អង្គការមិនមែនរដ្ឋាភិបាលនិងសហគមន៍អ្នកវិទ្យាសាស្រ្តជួបជុំគ្នាក្នុងកិច្ចពិភាក្សាអំពីតំបន់ដីសើមក្នុងតំបន់ដែលប្រារព្ធឡើងនៅក្រុងសៀមរាបចាប់ពីថ្ងៃទី ៣ ដល់ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៨។ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យបរិស្ថាននៅក្នុងប្រទេសកម្ពុជាបានក្រើករំលឹកឲ្យដឹងថាការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធដ៏ឆាប់រហ័សនេះអាចបំផ្លាញជោគជ័យនៃការអភិរក្ស និងការគ្រប់គ្រងតំបន់ដីសើមដែលបានខិតខំប្រឹងប្រែងជាច្រើនឆ្នាំកន្លងមកនេះ ជាមួយគ្នានេះដែរវាកំពុងគំរាមកំហែងដល់ភាពរីកចម្រើននៃការអភិវឌ្ឍន៍ដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់។

ដោយមានការកើនឡើងនូវបណ្តាគម្រោងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំៗ រួមទាំងគម្រោងអាជីវកម្មប្រេងកាតនៅតាមដែនសមុទ្រ គម្រោងស្ពានថ្នល់កាត់បឹងទន្លេសាប និងគម្រោងសាងសង់ទំនប់វារីអគ្គិសនីកាត់ដងទន្លេមេគង្គ និងដៃសំខាន់ៗរបស់វា កំពុងបង្កការគំរាមកំហែងយ៉ាងខ្លាំងក្លាដល់ជីវចម្រុះ ដីសើម និងសេវាកម្មនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដែលផ្តល់ឲ្យដោយទន្លេមេគង្គ និងដៃរបស់វា។

ដីសើមតាមតំបន់ឆ្នេរ និងតំបន់ទឹកសាបដែលគ្របដណ្តប់ជាង៣០%នៃផ្ទៃប្រទេសកម្ពុជាផ្តល់នូវផ្នែកមួយដ៏សំខាន់នៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភដល់ជាតិទាំងមូល។ ជលផល និងធនធានវារីសត្វរួមចំណែកជិត ៨០% នៃប្រូតេអ៊ីនសរុបដែលមាននៅក្នុងរបបអាហាររបស់ប្រជាជនកម្ពុជាយើងជាមួយគ្នានេះដែរស្រូវនិងប្រភេទដំណាំដែលជាអាហារមូលដ្ឋានផ្សេងៗទៀតដែលត្រូវបានដាំនៅតំបន់ដីសើម ដែលពឹងអាស្រ័យទាំងស្រុងលើប្រព័ន្ធអេកូឡូស៊ីដីសើមដែលមានសុខភាពល្អដើម្បីលូតលាស់។

បណ្ឌិត **ស្រី ស៊ុនលាង** ប្រធាននាយកដ្ឋាននៃតំបន់ដីសើមនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានមានប្រសាសន៍ថា "ធនធានដីសើមមានសារៈសំខាន់ចំពោះជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងកិច្ចអភិវឌ្ឍ ដោយចីរភាពរបស់ប្រទេស"។ "រដ្ឋាភិបាលកម្ពុជាបានចូលរួមក្នុងអនុសញ្ញា រ៉ាំសា ក្នុងឆ្នាំ១៩៩៩ ហើយប្តេជ្ញាចិត្តធ្វើការអភិរក្ស និងប្រើប្រាស់ធនធានដីសើមដ៏ឆ្លាតវៃនៅក្នុងប្រទេសកម្ពុជា"។

កង្វល់មួយក្នុងចំណោមកង្វល់ចំបងៗនាពេលនេះ គឺទំនប់ **ដន សាហុង** ដែលត្រូវបានស្នើសាងសង់ ហើយប្រសិនបើទំនប់នេះត្រូវបានសាងសង់ វារាំងស្កាត់ច្រកទឹកតែមួយគត់ដែលសមស្របសម្រាប់ការបំលាស់ទីរបស់ត្រី

នៅអាងទន្លេមេគង្គក្រោមក្នុងអំឡុងពេលពេញមួយឆ្នាំ និងគំរាមកំហែងដល់ធនធានជលផលទឹកសាបដ៏សំខាន់បំផុតរបស់ពិភពលោក និងរបរចញ្ចឹមជីវិតរបស់ប្រជាជនជាង៦០លាននាក់ដែលកំពុងរស់នៅក្នុងតំបន់អាងទន្លេមេគង្គក្រោម។

លោក **ឈិត សំអាត** នាយកអង្គការ WWF ប្រចាំប្រទេសកម្ពុជាបានមានប្រសាសន៍ថា "ប្រជាជនកម្ពុជាភាគច្រើនពឹងអាស្រ័យដោយផ្ទាល់លើប្រភពធនធានវារីសត្វដ៏សម្បូរណ៍បែបរបស់ប្រទេស។ យើងធ្វើការប៉ាន់ស្មានទុកជាមុនបានថា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយបែបនេះនឹងបង្កផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សេវាកម្មនៃប្រព័ន្ធអេកូឡូស៊ីតំបន់រ៉ាំសាខេត្តស្ទឹងត្រែងនិងតំបន់រ៉ាំសាបឹងឆ្មានៅបឹងទន្លេសាបរបស់ប្រទេសកម្ពុជាដែលនាំឲ្យបាត់បង់ជីវចម្រុះ និងឱកាសនៃការប្រកបរបរចញ្ចឹមជីវិត "។

បណ្ឌិត **Tracy Farrell** នាយកជាន់ខ្ពស់ផ្នែកបច្ចេកទេសរបស់អង្គការអភិរក្សអន្តរជាតិនៃមហាតំបន់មេគង្គបានមានប្រសាសន៍ថា "នៅពេលនេះ យើងកំពុងស្ថិតនៅលើដងវិថីមួយដ៏សំខាន់ដែលត្រូវឆ្លងកាត់ហើយយើងទន្ទឹងរង់ចាំកិច្ចប្រជុំថ្នាក់តំបន់អំពីដីសើមក្នុងគោលបំណងចាត់វិធានការដ៏មានប្រសិទ្ធភាពមួយក្នុងការពិនិត្យមើលលើគោលនយោបាយសម្របសម្រួល និងសកម្មភាពនានាពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីធានាឲ្យបានថា ដីសើមត្រូវបានអភិរក្ស ហើយយើងត្រូវជៀសវាងឲ្យបាននូវការបាត់បង់សេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលមិនអាចទទួលយកបាននោះ"។

ការគ្រប់គ្រងតំបន់ រ៉ាំសា ឲ្យមានប្រសិទ្ធភាពត្រូវបានស្នើសុំដ៏ទទូចដោយលេខាធិការដ្ឋាន រ៉ាំសា ហើយការគ្រប់គ្រងនេះចាប់ផ្តើមពីការប្រើផែនការគ្រប់គ្រងតាមបែបសម្របសម្រួលដ៏ល្អ ដែលគិតគូរអំពីតម្រូវការនានា ការបែងចែកតំបន់ការពារ និងតំបន់ប្រើប្រាស់ប្រកបដោយចីរភាព ក្នុងនោះមានរាប់បញ្ចូលទាំងតំបន់ការពារដ៏តឹងរឹងផងដែរ។ ក្រៅពីនេះ តំបន់ដែលត្រូវបានចាត់ទុក ជាតំបន់ស្នូលគឺជាកន្លែងដែលមានតម្លៃអភិរក្សខ្ពស់បំផុត ហើយការរំខានពីសកម្មភាពមនុស្សត្រូវតែកាត់បន្ថយឲ្យបានក្នុងកម្រិតអប្បបរិមាក្នុងគោលបំណងរក្សាឲ្យបាននូវភាពសម្បូរណ៍បែប នៃជិវិតសត្វ និងរុក្ខជាតិគ្រប់ប្រភេទទាំងអស់។

លោក **ម៉ូ ឧស្ណ័ក្ក** នាយកកម្មវិធីរបស់អង្គការសត្វស្លាបអន្តរជាតិបានឲ្យដឹងថា "យើងចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតដើម្បីគាំទ្ររដ្ឋាភិបាលលើការពិនិត្យមើលតំបន់ដីសើមនានាដែលមានសារៈសំខាន់ជាលក្ខណៈអន្តរជាតិដែលអាចកំណត់ជាតំបន់ រ៉ាំសា ថ្មីនៅក្នុងប្រទេសកម្ពុជា។ តំបន់ស្នូល ព្រែកទាល់នៃបឹងទន្លេសាបទទួលបានការឯកភាពគាំទ្រពីសំណាក់សហគមន៍មូលដ្ឋាន និងអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ ហើយតំបន់នេះអាចប្រែក្លាយជាតំបន់ រ៉ាំសា ទីបួននៅក្នុងប្រទេសកម្ពុជា"។ "ស្របពេលជាមួយគ្នានេះដែរ គេត្រូវតែដោះស្រាយនូវរាល់ការគំរាមកំហែង ចម្បងៗចំពោះតំបន់ដីសើម ក្នុងគោលបំណងធានាឲ្យបានថា វិធីសាស្ត្រអភិវឌ្ឍខុសៗគ្នាមិនមែនកំពុងដំណើរការដើម្បីប្រឆាំងនឹងគ្នាទៅវិញទៅមកនោះឡើយ"។

លោកបណ្ឌិត **Robert Mather** ប្រធានក្រុមអាស៊ីអាគ្នេយ៍នៃអង្គការ IUCN បានប្រសាសន៍ថា "យើងរំពឹងចូលរួមក្នុងកិច្ចប្រជុំតំបន់អាស៊ីស្តីពីអនុសញ្ញា រ៉ាំសា ក្នុងគោលបំណងពិចារណាលើហេតុប៉ះពាល់នៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល ដោយឈរលើកិច្ចខិតខំប្រឹងប្រែងជាសកលលើការអភិរក្សដីសើម និងគាំទ្រការរៀបចំសេចក្តីព្រាងអំពីការឆ្លើយតបទៅនឹងហេតុប៉ះពាល់ទាំងនោះដែលក្នុងនោះហត្ថលេខីនឹងមានកាតព្វកិច្ច

ពិនិត្យមើលសុខភាព មុខងារដ៏ពេញលេញ និងការប្រើប្រាស់ដ៏ឈ្លាសវៃនូវតំបន់រ៉ាំសាទាំងនោះ នៅពេលរៀបចំផែនការសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ឬថាមពលណាមួយនោះ”។

កិច្ចប្រជុំអំពីតំបន់ដីសើមអាស៊ី ដែលកំពុងប្រារព្ធធ្វើឡើងដំណាលគ្នានឹងសន្និសីទពិភាក្សាលើតំបន់ដីសើមអាស៊ីដែរនោះ ត្រូវបានរៀបចំប្រារព្ធឡើងនៅប្រទេសកម្ពុជាយើង។ នេះគឺជាការត្រួសត្រាយផ្លូវដើម្បីឈានទៅកាន់កិច្ចប្រជុំថ្នាក់សកលអំពីអនុសញ្ញា រ៉ាំសា ដែលគេរំពឹងប្រារព្ធធ្វើឡើងនៅប្រទេសអ៊ុយរ៉ាហ្គាយ នៅខែមិថុនា ឆ្នាំ២០១៥ ខាងមុខនេះ។

###

## ព័ត៌មានបន្ថែមសម្រាប់អ្នកនិពន្ធ

ដោយត្រូវបានចុះហត្ថលេខាដោយប្រទេសចំនួន ១៦៨ អនុសញ្ញា រ៉ាំសា គឺជាសន្ធិសញ្ញាអន្តររដ្ឋាភិបាលស្តីពីការអភិរក្ស និងការប្រើប្រាស់តំបន់ដីសើមប្រកបដោយនិរន្តរភាព។ នៅក្នុងកិច្ចប្រជុំអំពីតំបន់ដីសើមថ្នាក់តំបន់នាពេលខាងមុខនេះ រដ្ឋាភិបាលនៃប្រទេសចំនួន៣៣នៅក្នុងតំបន់អាស៊ី នឹងពិភាក្សាអំពីបញ្ហាគន្លឹះនានា និងពិនិត្យលើភាពរីកចម្រើននៃការអនុវត្តផែនការយុទ្ធសាស្ត្រតំបន់ រ៉ាំសា ឆ្នាំ១០០៩ - ២០១៥។ កិច្ចប្រជុំនេះនឹងរៀបចំសេចក្តីព្រាងនៃការឆ្លើយតបទៅនឹងហេតុប៉ះពាល់នានាដែលនឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអភិរក្សដីសើមសកលពីឆ្នាំ២០១៦តទៅ ដើម្បីយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំស្តីពីអនុសញ្ញា រ៉ាំសា អន្តរជាតិនៅប្រទេសអ៊ុយរ៉ាហ្គាយ នៅខែមិថុនា ឆ្នាំ២០១៥។

ចំណុចសំខាន់នៃការគិតគូរអំពីតំបន់ រ៉ាំសា គឺ "ការប្រើប្រាស់ប្រកបដោយភាពឆ្លាតវៃ" នៃតំបន់ដីសើម។ នៅពេលពួកទទួលស្គាល់អនុសញ្ញា ប្រទេសទាំងឡាយដែលបានចុះហត្ថលេខាលើសន្ធិសញ្ញា (ឬដែលហៅថាជាភាគីនៃកិច្ចសន្យា) ប្តេជ្ញាបំពេញការងារឆ្ពោះទៅកាន់ការប្រើប្រាស់ ប្រកបដោយភាពឈ្លាសវៃនូវប្រភពធនធានទឹក និងដីសើមនៅតាមប្រទេសរបស់ពួកគេ តាមរយៈការអនុវត្តផែនការជាតិ គោលនយោបាយនានា លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ សកម្មភាពគ្រប់គ្រង និងការអប់រំជាសាធារណៈ។

###

## <u>អំពីអង្គការ Birdlife International</u>

អង្គការសត្វស្លាបអន្តរជាតិ Birdlife International គឺជាដៃគូអភិរក្សធម្មជាតិដ៏ធំជាងគេមួយនៅលើពិភពលោក។ Birdlife មានដៃគូរបស់ខ្លួនចំនួន ១២០ នៅក្នុងពិភពលោកយើងនេះដែល ប្រទេសមួយតំណាងឲ្យដៃគូមួយ ឬបូរណៈភាពដែនដីមួយ ហើយចំនួនអ្នកគាំទ្រកើនឡើងដល់ទៅជិត១១ លាននាក់ និងមានក្រុមអភិរក្សមូលដ្ឋានចំនួន៧០០០ក្រុម រួមជាមួយបុគ្គលិកសរុបចំនួន៧៥០០រូប។ ចក្ខុវិស័យរបស់អង្គការ Birdlife គឺពិភពលោកមួយដែលសំបូរទៅដោយជីវ-ចម្រុះដែលមនុស្ស និងធម្មជាតិរស់នៅជាមួយគ្នា។ យើងត្រូវបានដឹកនាំដោយជំនឿរបស់យើងដែលប្រជាជនមូលដ្ឋានដែលជាអ្នកបំពេញការងារដើម្បីការពារធម្មជាតិនៅកន្លែងរបស់ខ្លួនដោយមានទំនាក់ទំនងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិតាមរយៈភាពជាដៃគូជាសកលរបស់យើងគឺជាគន្លឹះដើម្បីធានានូវភាពគង់វង្សនៃជីវិត

នៅលើផែនដី។ វិធីសាស្ត្រពីមូលដ្ឋានទៅកាន់សាកលលោកដ៏ពិសេសនេះសម្រេចបាននូវលទ្ធផលដ៏ពេញចិត្ត និងធានាបាននូវការអភិរក្សរយៈពេលវែងដើម្បី ផលប្រយោជន៍របស់ធម្មជាតិ និងប្រជាជន។

**សម្រាប់ព័ត៌មានបន្ថែម៖**

លោក **ប៊ូ វរស័ក្តិ** នាយកគ្រប់គ្រងកម្មវិធីនៃអង្គការ Birdlife International នៅក្នុងប្រទេសកម្ពុជា

ទូរស័ព្ទ៖ + ៨៥៥ ២៣ ៩៩៣ ៦៣១ អ៊ីមែល៖ vorsak.bou@birdlife.org

ហ្វេសប៊ុក៖ Birdlife International Cambodia Program

###

**អំពីអង្គការ Conservation International**

ត្រូវបានបង្កើតឡើងដោយមានមូលដ្ឋានគ្រឹះរឹងមាំផ្នែកវិទ្យាសាស្ត្រ ភាពជាដៃគូ និងស្រែបង្ហាញ អង្គការ Conservation International ផ្តល់អំណាចដល់សង្គមក្នុងការយកចិត្តទុកដាក់ចំពោះធម្មជាតិប្រកបដោយទទួលខុសត្រូវ និងនិរន្តរភាព ដើម្បីសុខមាលភាពរបស់មនុស្សជាតិ។

**សម្រាប់ព័ត៌មានបន្ថែម៖**

Emmeline Johansen អ្នកគ្រប់គ្រងផ្នែកប្រព័ន្ធផ្សព្វផ្សាយ ejohansen.conservation@gmail.com

###

**អំពីអង្គការ IUCN (អង្គការសហភាពអន្តរជាតិដើម្បីអភិរក្ស ធម្មជាតិនិងធនធានធម្មជាតិ)**

អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិនិងធនធានធម្មជាតិគឺជាបណ្តាញបរិស្ថានសកលដែលធំនិងចំណាស់ជាងគេនៅលើពិភពលោក ដែលជាសហភាពមួយដែលមានការចូលរួមពីរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលចំនួនជាង១២០០ស្ថាប័ន ហើយនិងមានអ្នកវិទ្យាសាស្ត្រស្ម័គ្រចិត្តជាង១១០០០នាក់មកពីបណ្តា១៦០ប្រទេស។ ការងាររបស់អង្គការ IUCN គឺត្រូវបានគាំទ្រដោយបុគ្គលិកជំនាញជាង ១០០០នាក់ មកពីការិយាល័យចំនួន ៦០និង ជាងរាប់រយពី ស្ថាប័នរដ្ឋ អង្គការនិង វិស័យឯកជននៅជុំវិញពិភពលោក។

**សម្រាប់ព័ត៌មានបន្ថែម**

លោក គង់ គឹមស្រេង

អ៊ីមែល: Kimsreng.KONG@iucn.org

###

**អំពីអង្គការ WCS**

អង្គការសមាគមន៍អភិរក្សសត្វព្រៃគឺមានភារកិច្ចចំបងក្នុងការជួយសង្គ្រោះសត្វព្រៃនិងជំរកសត្វព្រៃលើពិភពលោកដោយផ្អែកលើ វិទ្យាសាស្ត្រ សកម្មភាពអភិរក្ស ការអប់រំ និង ជំរុញមនុស្សអោយផ្តល់តម្លៃទៅលើធម្មជាតិ។

**សម្រាប់ព័ត៌មានបន្ថែម**

Ross Sinclair (Mr.) ប្រធានកម្មវិធីប្រចាំកម្ពុជា

អ៊ីមែល: rsinclair@wcs.org

###

**អំពីអង្គការ WWF (មូលនិធិសកលសម្រាប់ធនធានធម្មជាតិ)**

អង្គការ WWF គឺជាអង្គការមួយក្នុងចំណោមអភិរក្សឯករាជ្យដែលទទួលបានការកោតសរសើរច្រើនជាងគេនិងធំជាងគេបំផុតនៅលើពិភពលោក ដែលមានអ្នកគាំទ្រជាងប្រាំលាននាក់ និង ជាបណ្តាញសាកលមួយដែលមានភាពសកម្មនៅក្នុងជាង ១០០ ប្រទេស។ បេសកកម្មរបស់ WWF គឺដើម្បីបញ្ឈប់ការរិចរិលនៃបរិស្ថានធម្មជាតិរបស់ភពផែនដី និងកសាងអនាគតដែលមនុស្សរស់នៅដោយភាពសុខដុមរមនាជាមួយធម្មជាតិ ដោយអភិរក្សជីវចម្រុះ របស់ពិភពលោក ធានាថាការប្រើប្រាស់ធនធានធម្មជាតិកកើតឡើងវិញ គឺមាននិរន្តរភាព និងលើកកម្ពស់ការកាត់បន្ថយការបំពុល និងប្រើប្រាស់ដោយការខ្ជះខ្ជាយ។

**សម្រាប់ព័ត៌មានបន្ថែម**

លោក **ឈិត សំអាត** នាយកអង្គការ WWF កម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤ អ៊ីមែល៖ SamAth.Chhith@wwfgreatermekong.org